ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សភាស៊ើបសួរ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៤០
ចុះថ្ងៃទី ២០-០២-២០២៣
<u>សាលដីកា</u>
លេខ: ៦ "ក្រ.III.ជំហ "
ចុះថ្ងៃទី ០៧-៤-២០២៣

# គោរពនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានធ្វើការពិភាក្សាដេញដោលជាអសាធារណៈ នៅបន្ទប់ពិភាក្សានៃសាលាឧទ្ធរណ៍ភ្នំពេញ នាថ្ងៃសុក្រ ២រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី០៧ ខែ មេសា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

កញ្ញា [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

[redacted]

ដើម្បីដំណើរការកិច្ចពិភាក្សាដេញដោល លើបណ្តឹងសុំមោឃភាព នៃរឿងសភាស៊ើបសួរលេខ: ៤០ ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០២៣ ដែលមាន:

-ជនត្រូវចោទឈ្មោះ [redacted] ពន្លឺ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត [redacted]រាជធានីភ្នំពេញ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ [redacted]រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) នៅលើវ ជាអនីតិជន ប្រវត្តិនៃកាផ្តន្ទាទោសដោយតុលាការ (ធ្លាប់ជាប់នៅមណ្ឌលឱកាសខ្ញុំរយៈពេល១ខែកន្លះ កាលពីឆ្នាំ២០១៩)។

មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទ លោក [redacted] បូរ៉ា ។

<u>ត្រូវបានដាក់ស្ថិតនៅក្រោមការពិនិត្យពីបទៈ</u> ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខណោត ផ្លូវបេតុង សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

**ការប្រព្រឹត្តរបស់ជនត្រូវចោទមានដូចតទៅ:**

កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង១៨ និង៥០នាទី កម្លាំងជំនាញការិយាល័យស្រាវជ្រាវនៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន បានធ្វើការបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចមុខណោត ផ្លូវបេតុង សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដោយបានឃាត់ខ្លួនជនត្រូវចោទចំនួន០២នាក់ ឈ្មោះ [redacted] ពន្លឺ ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] បូរ៉ា ភេទប្រុស អាយុ៤០ឆ្នាំ និងបានដកហូតវត្ថុតាងក្រោមពណ៌សថ្លាសង្ស័យជាសារធាតុញៀនប្រភេទមេតំហ្វេតាមីនចំនួន ០១កញ្ចប់តូច ទម្ងន់១,២៧ក្រាម និងទូរស័ព្ទដៃម៉ាក SAMSUNG ចំនួន ០១គ្រឿង។ ក្រោយមកកម្លាំងសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនសង្ស័យខាងលើ រួមនឹងវត្ថុតាងយកមកសាកសួរនៅមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន ដើម្បីសាកសួរ និងចាត់ការតាមនីតិវិធីច្បាប់។

តាមពាក្យស្នើសុំមោឃកម្ម ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ របស់លោក [redacted] បូរ៉ា មេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] ពន្លឺ ស្នើសុំមោឃភាពឯកសារនៃនីតិវិធីមួយចំនួនក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៥៨៦៦ ដែលមានអំណះអំណាង និងសំណូមពរថា៖ ពន្លឺ មានអាយុ១៧ឆ្នាំ ត្រូវបានដាក់ក្រោមការស៊ើបអង្កេត និងឃុំខ្លួន ពីបទជួញដូរនូវសារធាតុញៀនខុសច្បាប់ និងប្រើប្រាស់សារធាតុញៀន តាមមាត្រា៤០ និង៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន ឆ្នាំ២០១២។ ទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌ អនុវត្តក្នុងរឿងនេះក្តី ក៏ប៉ុន្តែដោយសារពន្លឺ ជាអនីតិជន តាមមាត្រា២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលចែងថា ច្បាប់ស្តីពីយុត្តិធម៌អនីតិជនជាច្បាប់ពិសេស នីតិវិធីត្រូវអនុវត្តសម្រាប់ ពន្លឺ ជាដំបូងគឺអនុលោមតាមច្បាប់នេះ។ តាមមាត្រា២២ (ការស្តាប់យកចម្លើយ) មាត្រា២៦ (ការស្តាប់យកចម្លើយ) និងមាត្រា៣៥ (ការស្តាប់យកចម្លើយ) នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដោយនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ តម្រូវឱ្យមានវត្តមានរបស់មេធាវី និងភ្នាក់ងារសង្គមកិច្ច ឯកសារពាក់ព័ន្ធក្នុងសំណុំរឿងនេះមិនបានបង្ហាញថា នគរបាលបានប្រាប់អំពីសិទ្ធិមានមេធាវី មិនបានបង្ហាញថា មានការជូនដំណឹងដល់អាណាព្យាបាល ឬមានការបដិសេធមិនឱ្យពួកគេចូលដោយសារឧត្តមប្រយោជន៍កុមារ ក្រោយពីបានពិគ្រោះយោបល់ជាមួយមេធាវី។ បន្ថែមពីលើនេះ ក៏មិនបានចុះនិទ្ទេសក្នុងឯកសារពាក់ព័ន្ធ តម្រូវដោយមាត្រា២២ ផងដែរ។ នៅក្នុងអំឡុងពេលសួរចម្លើយ ពន្លឺ បានអះអាងថា គាត់ត្រូវបានបង្ខំឱ្យឆ្លើយ មិនបានអានខ្លឹមសារឱ្យស្តាប់ និងបង្ខំឱ្យផ្តិតមេដៃ ខ្លឹមសារនេះត្រូវបានសរសេរក្នុងកំណត់ហេតុសួរចម្លើយ របស់អយ្យការក្នុងថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ ដែល ពន្លឺ បានបដិសេធនូវចម្លើយឆ្លើយមុខសមត្ថកិច្ច។ ឯកសារទាំងនោះ ត្រូវបានធ្វើឡើងដោយគ្មានវត្តមានមេធាវី មិនបានប្រាប់សិទ្ធិ ឬចុះនិទ្ទេសដូចបានតម្រូវដោយមាត្រា២៦ ដែលព្រះរាជអាជ្ញាត្រូវតែគោរព។ ពន្លឺ បានទទួលស្គាល់ថាគាត់បានប្រើប្រាស់សារធាតុញៀន ក៏ប៉ុន្តែមិនបានជួញដូរទេ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនបានសរសេរអំពីការពិចារណានូវការលើកឡើងនេះ។ ពន្លឺ បានអះអាងដូចគ្នានៅមុខចៅក្រមស៊ើបសួរ ពេលឃាត់ខ្លួន គាត់មិនមានសារធាតុញៀន នគរបាលបង្ខំឱ្យគាត់ផ្តិតមេដៃទទួល។ ការបង្ហាញខ្លួនលើកដំបូងនៅមុខចៅក្រមស៊ើបសួរ ក្នុងថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២២ មិនបង្ហាញថា មានការប្រាប់នូវសិទ្ធិមានមេធាវីទេ។ កំណត់ហេតុស្តីពីការពិភាក្សាដេញដោលឈានទៅរកការឃុំខ្លួនក៏គ្មានវត្តមានរបស់មេធាវី ទាំងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរប្រចាំការ មិនបាន

Scanned with CamScanner

ពិចារណាហ្មត់ចត់នូវការបដិសេធចម្លើយ ឬចម្លើយដោយបង្ខំ អះអាងដោយពន្លឺទេ។ ទង្វើខាងលើ ជាពិសេសការបង្ខំឱ្យឆ្លើយ ឬឆ្លើយដោយមិនមានវត្តមានមេធាវី ដែលឈានទៅដល់ការចោទពីបទ ជួញដូរនូវសារធាតុញៀន ជាប់ពន្ធនាគារ ពី២ឆ្នាំ ទៅ៥ឆ្នាំ អាចអនុញ្ញាតឱ្យឃុំខ្លួនបាន និងដាក់អនីតិជនចូលក្នុងនីតិវិធីជាបន្តបន្ទាប់ក្រោយមក នាំឱ្យបំពានសិទ្ធិ ចែងក្នុងមាត្រា៥ និងមាត្រា៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលអះអាងថា ការឃុំខ្លួនអនីតិជនត្រូវតែជាជម្រើសចុងក្រោយ និងក្នុងរយៈពេលខ្លីបំផុត, ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្តន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន។ ទង្វើខាងលើ បានបំពានមាត្រា២២ មាត្រា២៦ ដែលតាមខ្លឹមសារមាត្រានេះ នាំឱ្យមានមោឃភាពដាច់ខាត។ អនុលោមតាមមាត្រាទាំងនេះក្នុងគោលបំណងការពារសិទ្ធិជនត្រូវចោទ ខ្លួនស្នើសុំឱ្យសភាស៊ើបសួរ ធ្វើមោឃកម្មនូវឯកសារមួយចំនួន និងឯកសារពាក់ព័ន្ធ ដែលទទួលបានពីឯកសារមានមោឃភាព ជាពិសេស៖

១.កំណត់ហេតុឃាត់ខ្លួនពីបទល្មើសជាក់ស្តែង ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២

២.កំណត់ហេតុបិទកញ្ចប់ភស្តុតាង ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២

៣.កំណត់ហេតុស្តាប់ចម្លើយ នៅមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២

៤.កំណត់ហេតុស្តីពីការឃាត់ខ្លួន ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២

៥.កំណត់ហេតុដកហូតសម្ភារៈ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ៤៤៣៤ អ.យ.ធ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ: ៧២៧៩ (ន) ដពស ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២២របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ពាក្យស្នើសុំមោឃកម្ម ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ របស់លោក [redacted] បូរ៉ា មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ពន្លឺ ។

-បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ របស់សភាស៊ើបសួសាលាឧទ្ធរណ៍ភ្នំពេញ។

-បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

## នាពេលសវនាការ

-ជនត្រូវចោទឈ្មោះ [redacted] ពន្លឺ (វត្តមាន)

មេធាវីការពារឱ្យជនត្រូវចោទ លោក [redacted] បូរ៉ា (វត្តមាន)

ប្រធានក្រុមប្រឹក្សា អានរបាយការណ៍សង្ខេបរឿង

-ជនត្រូវចោទឈ្មោះ [redacted] ពន្លឺ ឆ្លើយថា: មន្ត្រីនគរបាលយុត្តិធម៌ បានឃាត់ខ្លួន ពាក់ព័ន្ធនឹងបទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។ នៅពេលសាកសួរខ្លួនអត់បានស្នើសុំរកមេធាវីទេ ហើយខ្លួនពុំបាន

Scanned with CamScanner

បដិសេធក្នុងការផ្តល់ចម្លើយ នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ដែរ។ នៅពេលសួរចម្លើយអត់មានវត្តមានម្តាយខ្លួន និងមេធាវីចូលរួមទេ ហើយពេលសាកសួរចប់ក៏អត់បានអានឱ្យខ្លួនស្តាប់ តែឱ្យខ្លួនផ្តិតមេដៃ។

-ឈ្មោះ [redacted] សុធារី ឆ្លើយថា ខ្លួនត្រូវជាម្តាយរបស់ជនត្រូវចោទ [redacted]ពន្លឺ។ ខ្លួនមិនបានចូលរួមទេ ក្នុងពេលនគរបាលសាកសួរចម្លើយកូនខ្លួន។

-សេចក្តីកត់សម្គាល់របស់តំណាងមហាអយ្យការៈ ក្រោយពីការសាកសួរជនត្រូវចោទ ក៏ដូចជាអាណាព្យាបាលជនត្រូវចោទ និងការលើកបង្ហាញមួយចំនួនរបស់មេធាវី [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ ក៏ដូចជាការមើលឯកសារឃើញថារឿងនេះតាំងពីដំណាក់កាល មន្ត្រីនគរបាលយុត្តិធម៌ គឺជនត្រូវចោទត្រូវបានសួរចម្លើយដោយមិនមានវត្តមានមេធាវី និងមិនមានការជូនដំណឹងទៅអាណាព្យាបាលនោះទេ ក៏ដូចជាកំណត់ហេតុនៃការសួរចម្លើយក៏បានបញ្ជាក់យ៉ាងច្បាស់ថាមិនមានវត្តមានមេធាវីចុះហត្ថលេខា ឬក៏អាណាព្យាបាលនោះដែរ ដូច្នេះក្នុងរឿងនេះផ្អែកតាមមាត្រា១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលលោកមេធាវីបានប្តឹងមោឃភាពនឹងកំណត់ហេតុចំនួន៥ ដែលមានចែងក្នុងមាត្រា១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ យើងតំណាងមហាអយ្យការយល់ឃើញថា អ្វីដែលមិនស្របច្បាប់ មិនត្រឹមត្រូវតាមនីតិវិធី ហើយដែលយើងអាចមោឃភាពបាន មានតែ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកសារលេខ:១.២៣, កំណត់ហេតុឃាត់ខ្លួនពីបទល្មើសជាក់ស្តែង ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកសារលេខ:១.២៦, កំណត់ហេតុស្តីពីការឃាត់ខ្លួន ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកសារលេខ: ១,១១ ដែលជាកំណត់ហេតុមួយដែលអនុវត្តមិនត្រូវតាមមាត្រា១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដូច្នេះនាំឱ្យមានការមោឃភាព លើកំណត់ហេតុ៣ នេះ ដូច្នេះតំណាងអយ្យការស្នើសុំមោឃភាពលើកំណត់ហេតុ៣ ចំណែកឯ ២ ទៀតទុកឱ្យក្រុមប្រឹក្សាសម្រេចពិចារណាតាមផ្លូវច្បាប់ ។

មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ ធ្វើសេចក្តីសន្និដ្ឋានថា: តាមកំណត់ហេតុភ្ជាប់ និងវត្ថុតាង មានចែងក្នុងមាត្រា១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងពីបញ្ហាមោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ។ មោឃភាពអាចធ្វើទៅបានដោយសារវាមិនជាប់ទៅនឹងបណ្តឹងឧទ្ធរណ៍។ ចំពោះខ្លឹមសារ ទី១ ដោយសារទាក់ទងទៅនិងអនីតិជន យើងត្រូវប្រើច្បាប់ពិសេស ដែលច្បាប់ស្តីពីយុត្តិធម៌អនីតិជន ហើយក្នុងមាត្រា២២ ខ្លួនបានដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរជូនឯកឧត្តមរួចហើយ ដែលមានការប្រាប់សិទ្ធិមុននិងសួរ និងវត្តមានមេធាវីហើយប្រសិនបើគាត់មិនបានចូលរួមទេ ត្រូវអានឱ្យគាត់ស្តាប់ ប្រសិនបើគាត់មិនចេះអាន ហើយបើតាមខ្លឹមសារដដែលនេះ ចំណុចទាំងអស់នេះបើគាត់ខ្វះខាតកន្លែងណា គឺនាំឱ្យមានមោឃភាពដាច់ខាត ចឹងហើយបានដើម្បីការពារកូនក្តី មេធាវីបានសិក្សាលើច្បាប់ដែលពាក់ព័ន្ធ ជាញត្តិដើម្បីសូមឱ្យអង្គជំនុំជម្រះ ពិចារណាមោឃភាពឯកសារមួយចំនួន ដូចខ្លួនបានបញ្ជាក់ដែលថាពន្លឺគាត់បានប្រើពិតមែន ប៉ុន្តែដោយឡែករឿងជួញដូរ ពេលដែលចាប់នោះគឺគាត់មិនមានអ្វីក្នុងខ្លួននោះទេ តែតាមរបាយការណ៍ចេញមកមាន១កញ្ចប់តូច។ គាត់ទទួលស្គាល់ថាបានប្រើប្រាស់តែគាត់មិនបានជួញដូរនោះទេ។ សូមសំណូមពរសុំឯកឧត្តមពិចារណា លើឯកសារមួយចំនួនដែលធ្វើឡើងខុសនីតិវិធី តាមក្រមនីតិវិធីព្រហ្មទណ្ឌ ជាឆន្ទានុសិទ្ធិ របស់ឯកឧត្តមប្រធានក្រុមប្រឹក្សា បើសិនរកឃើញឯកសារដទៃទៀត ក៏អាចមានសិទ្ធិក្នុងការធ្វើមោឃភាពបានដែរ។

-ក្រោយពីបានស្តាប់ចម្លើយជនត្រូវចោទ និងម្តាយរបស់ជនត្រូវចោទ

-ក្រោយពីបានស្តាប់ការកត់សម្គាល់របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សភាស៊ើបសួរ
## យល់ឃើញថា:

១-ពាក្យស្នើសុំមោឃកម្ម ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ របស់លោក [redacted] បូរ៉ា មេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] ពន្លឺ សុំមកសភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ បានធ្វើឡើងត្រឹមត្រូវតាមច្បាប់ សភាស៊ើបសួរទទួលពិភាក្សាដេញដោលបាន យោងតាមមាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-ជនត្រូវចោទត្រូវបានដាក់ស្ថិតក្រោមការត្រួតពិនិត្យ ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខណោត ផ្លូវបេតុង សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ជនត្រូវចោទឈ្មោះ [redacted] ពន្លឺ បានឆ្លើយថា: មន្ត្រីនគរបាលយុត្តិធម៌ បានឃាត់ខ្លួន ពាក់ព័ន្ធនឹងបទល្មើសជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។ នៅពេលសាកសួរខ្លួនអត់បានស្នើសុំរកមេធាវីទេ ហើយខ្លួនពុំបានបដិសេធក្នុងការផ្តល់ចម្លើយ នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ដែរ។ នៅពេលសួរចម្លើយអត់មានវត្តមានម្តាយខ្លួន និងមេធាវីចូលរួមទេ ហើយពេលសាកសួរចប់ក៏អត់បានអានឱ្យខ្លួនស្តាប់ តែឱ្យខ្លួនផ្តិតមេដៃ។

៤-តំណាងមហាអយ្យការធ្វើការកត់សម្គាល់ថា: ក្រោយពីការសាកសួរជនត្រូវចោទ ក៏ដូចជាអាណាព្យាបាលជនត្រូវចោទ និងការលើកបង្ហាញមួយចំនួនរបស់មេធាវី [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ ក៏ដូចជាការមើលឯកសារឃើញថារឿងនេះតាំងពីដំណាក់កាល មន្ត្រីនគរបាលយុត្តិធម៌ គឺជនត្រូវចោទត្រូវបានសួរចម្លើយដោយមិនមានវត្តមានមេធាវី និងមិនមានការជូនដំណឹងទៅអាណាព្យាបាលនោះទេ ក៏ដូចជាកំណត់ហេតុនៃការសួរចម្លើយក៏បានបញ្ជាក់យ៉ាងច្បាស់ថាមិនមានវត្តមានមេធាវីចុះហត្ថលេខា ឬក៏អាណាព្យាបាលនោះដែរ ដូច្នេះ ក្នុងរឿងនេះផ្អែកតាមមាត្រា១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលលោកមេធាវីបានប្តឹងមោឃភាពនឹងកំណត់ហេតុចំនួន៥ ដែលមានចែងក្នុងមាត្រា១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ យើងតំណាងមហាអយ្យការយល់ឃើញថា អ្វីដែលមិនស្របច្បាប់ មិនត្រឹមត្រូវតាមនីតិវិធី ហើយដែលយើងអាចមោឃភាពបាន មានតែ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកសារលេខ:១.២៣, កំណត់ហេតុឃាត់ខ្លួនពីបទល្មើសជាក់ស្តែង ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកសារលេខ:១.២៦, កំណត់ហេតុស្តីពីការឃាត់ខ្លួន ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកសារ លេខ:១,១១ ដែលជាកំណត់ហេតុមួយដែលអនុវត្តមិនត្រូវតាមមាត្រា១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដូច្នេះនាំឱ្យមានការ

Scanned with CamScanner

មោឃភាព លើកំណត់ហេតុ៣ នេះ ដូច្នេះតំណាងអយ្យការស្នើសុំមោឃភាពលើកំណត់ហេតុ៣ ចំណែកង ២ទៀត ទុកឲ្យក្រុមប្រឹក្សាសម្រេចពិចារណាតាមផ្លូវច្បាប់ ។

៥-មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទ ធ្វើសេចក្តីសន្និដ្ឋានថា: តាមកំណត់ហេតុភ្ជាប់ និងវត្ថុតាង មានចែងក្នុងមាត្រា១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងពីបញ្ហាមោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ។ មោឃភាពអាចធ្វើទៅបានដោយសារវាមិនជាប់ទៅនឹងបណ្តឹងឧទ្ធរណ៍។ ចំពោះខ្លឹមសារ ទី១ ដោយសារទាក់ទងទៅនិងអនីតិជន យើងត្រូវប្រើច្បាប់ពិសេស ដែលច្បាប់ស្តីពីយុត្តិធម៌អនីតិជន ហើយក្នុងមាត្រា២២ ខ្លួនបានដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរជូនឯកឧត្តមរួចហើយ ដែលមានការប្រាប់សិទ្ធិមុននិងសួរ និងវត្តមានមេធាវីហើយប្រសិនបើគាត់មិនបានចូលរួមទេ ត្រូវអានឲ្យគាត់ស្តាប់ ប្រសិនបើគាត់មិនចេះអាន ហើយបើតាមខ្លឹមសារដដែលនេះ ចំណុចទាំងអស់នេះបើគាត់ខ្វះខាតកន្លែងណា គឺនាំឲ្យមានមោឃភាពដាច់ខាត ចឹងហើយបានដើម្បីការពារកូនក្តី មេធាវីបានសិក្សាលើច្បាប់ដែលពាក់ព័ន្ធ ជាញត្តិដើម្បីសូមឲ្យអង្គជំនុំជម្រះ ពិចារណាមោឃភាពឯកសារមួយចំនួន ដូចខ្លួនបានបញ្ជាក់ដែលថាពន្លឺគាត់បានប្រើពិតមែន ប៉ុន្តែដោយខ្សែករឿងជួញដូរ ពេលដែលចាប់នោះគឺគាត់មិនមានអ្វីក្នុងខ្លួននោះទេ តែតាមរបាយការណ៍ចេញមកមាន១កញ្ចប់តូច។ គាត់ទទួលស្គាល់ថាបានប្រើប្រាស់តែគាត់មិនបានជួញដូរនោះទេ។ សូមសំណូមពរសុំឯកឧត្តមពិចារណា លើឯកសារមួយចំនួនដែលធ្វើឡើងខុសនីតិវិធី តាមក្រមនីតិវិធីព្រហ្មទណ្ឌ ជាឆន្ទានុសិទ្ធិ របស់ឯកឧត្តមប្រធានក្រុមប្រឹក្សា បើសិនរកឃើញឯកសារដទៃទៀត ក៏អាចមានសិទ្ធិក្នុងការធ្វើមោឃភាពបានដែរ។

៦-យោងមាត្រា៩៣ និងមាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា មន្ត្រីនគរបាលយុត្តិធម៌ អាចហៅ និងនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូប ដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស និងធ្វើការស្តាប់ចម្លើយជននោះ។ រីឯមាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានបញ្ជាក់ថា បុគ្គលដែលត្រូវឃាត់ខ្លួនអាចស្នើសុំសន្ទនាជាមួយមេធាវី ក្រោយឃាត់ខ្លួនរយៈពេល២៤ម៉ោង ប៉ុន្តែផ្អែកតាមកំណត់ហេតុឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted]ពន្លឺ ពុំបានស្នើសុំទៅមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីធ្វើការសន្ទនាជាមួយមេធាវីរបស់ខ្លួនឡើយ។ តាមការពិនិត្យលើកំណត់ហេតុស្តាប់ចម្លើយ របស់ជនត្រូវចោទឈ្មោះ [redacted] និងការស្តាប់ចម្លើយជនត្រូវចោទនាពេលពិភាក្សា ឃើញថា មន្ត្រីនគរបាលយុត្តិធម៌ពុំបានអនុញ្ញាតឲ្យម្តាយរបស់ជនត្រូវចោទចូលរួមពេលសាកសួរចម្លើយឡើយ យោងមាត្រា២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន តម្រូវឲ្យមានមេធាវីដាច់ខាតនៅពេលសួរចម្លើយជនត្រូវចោទ។ គប្បីតុលាការចាត់ទុកជាមោឃៈនូវ៖ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកសារលេខ:១.២៣។

-ចំពោះកំណត់ហេតុផ្សេងទៀត ពុំមានលក្ខណៈដាច់ខាត ដែលត្រូវធ្វើមោឃភាពឡើយ។

## ហេតុដូច្នេះ

## សម្រេច

១-ទទួលមួយផ្នែកនូវពាក្យស្នើសុំមោឃកម្ម (មោឃភាព) ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ របស់លោក [redacted]បូរ៉ា មេធាវីការពារសិទ្ធិឲ្យឈ្មោះ [redacted]ពន្លឺ ដែលបានស្នើសុំមកសភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ។

Scanned with CamScanner

២-ចាត់ទុកជាមោឃៈនូវកំណត់ហេតុស្តាប់ចម្លើយ ជនត្រូវចោទឈ្មោះ [redacted] ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០២២ របស់មន្ត្រីនគរបាលយុត្តិធម៌ នៃមន្ទីរប្រឆាំងគ្រឿងញៀន។

៣.ឲ្យដកកំណត់ហេតុស្តាប់ចម្លើយខាងលើនេះចេញពីសំណុំរឿងហើយតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជី នៃសភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ។

៤.បដិសេធចោលនូវការស្នើសុំផ្សេងទៀត។

សាលដីកានេះ ពិភាក្សាសួរដេញដោល និងប្រកាសជាអសាធារណៈ នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

.............................................................................................................................................

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ២រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

ភ្នំពេញ, ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner